ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

Economic Development Cooperation Fund

ថ្ងៃ សុក្រ ១ រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ២០២២

# សេចក្តីប្រកាសព័ត៌មានរួម
## ស្តីពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានសម្បទានចំនួន ២ ពីសាធារណរដ្ឋកូរ៉េ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

នាព្រឹកថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០២២, នៅវិមានសន្តិភាព, **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់បំផុត ក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្នុងការផ្តល់ឥណទានសម្បទាន**ចំនួន ២** ពីសាធារណរដ្ឋកូរ៉េ រវាង **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលោកស្រី Minnie Chey ប្រធានតំណាងមូលនិធិសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍសេដ្ឋកិច្ច នៃធនាគារនីហរ័ណ អាហរ័ណកូរ៉េ (EDCF/ Korea Eximbank) ប្រចាំនៅកម្ពុជា ។ កិច្ចព្រមព្រៀងឥណទានសម្បទានទាំងពីរ មាន÷

*<u>កិច្ចព្រមព្រៀងទី ១:</u> សម្រាប់គម្រោងពង្រឹងសមត្ថភាពប្រព័ន្ធបណ្តាញបញ្ជូនអគ្គិសនី នៅខេត្តព្រះសីហនុ [Grid Reinforcement in Sihanoukville Project] មានទឹកប្រាក់ឥណទានចំនួន ៧០ 000 000 ដុល្លារអាមេរិក*

វិសាលភាពរបស់គម្រោង គឺសាងសង់ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់នៅលើអាកាស និងបង្កប់ក្រោមដីចំនួន ៣ ខ្សែ ប្រវែងសរុបចំនួន ២២ គ.ម, សាងសង់អនុស្ថានីយចំនួន ៤ កន្លែង និង ពង្រីកអនុស្ថានីយចំនួន ២ កន្លែង។ គម្រោងនេះ មានរយៈពេលអនុវត្តចំនួន ៤ ឆ្នាំ ៥ ខែ (៥៤ ខែ) និងរយៈពេលសាងសង់ចំនួន ៣ ឆ្នាំ (៣៦ ខែ)។

*<u>កិច្ចព្រមព្រៀងទី ២:</u> សម្រាប់គម្រោងសាងសង់ស្ពានមិត្តភាពកម្ពុជា-សាធារណរដ្ឋកូរ៉េ (ផ្សាររាត្រី-ជ្រោយចង្វារ; ជ្រោយចង្វារ - អរិយក្សត្រ) [Cambodia-Korea Friendship Bridge Project ] មានទឹកប្រាក់ឥណទានចំនួន ២៤៥ ៩០៩ 000 ដុល្លារអាមេរិក*

វិសាលភាពរបស់គម្រោង គឺសាងសង់ស្ពានចំនួន ២ នៅទីតាំង *"ផ្សាររាត្រី- ជ្រោយចង្វារ និង ជ្រោយចង្វារ-អរិយក្សត្រ"* ជាស្ពានប្រភេទខ្សែកាបយោងខ្ពស់ (Cable-Stayed Bridge) សាងសង់ជា ៤ គន្លង (4 Lanes)

ប្រភេទ A/C, ទទឹងស្ពានមានប្រវែងសរុប ២៧,៥ ម៉ែត្រ និងទទឹងផ្លូវប្រវែង ២២,៥ ម៉ែត្រ ដែលមានមេដ្យាន ៣ ម៉ែត្រ និងចិញ្ចើមផ្លូវ ៣ ម៉ែត្រ (៣,០-៣,៥-៣,៥ [៣,០] ៣,៥-៣,៥-៣,០), ល្បឿនអតិបរមា ៨០ គ.ម/ម៉ោង ក្នុងនោះ÷

- ស្ពានទី ១÷ ឆ្លងកាត់ទន្លេសាប (ចាប់ផ្តើមពីចំណុចម្តុំស្ទួនផ្សាររាត្រី (ផ្សារចាស់) ឆ្លងកាត់ទៅត្រើយម្ខាងជ្រោយចង្វារ (ក្បែរសណ្ឋាគារសុខា) មានប្រវែង ១,១៩ គ.ម និង
- ស្ពានទី ២÷ ឆ្លងកាត់ទន្លេមេគង្គ ចាប់ផ្តើមពីចំណុចត្រើយម្ខាងជ្រោយចង្វារ (ក្បែរសណ្ឋាគារសុខា) ឆ្ពោះទៅប្រសព្វនឹងផ្លូវលេខ ៣៨០ ឃុំអរិយក្សត្រ (ស្រុកល្វាឯម/ខេត្តកណ្តាល) មានប្រវែង ១,១៨ គ.ម និងផ្លូវតភ្ជាប់ទៅផ្លូវប្រសព្វនឹងផ្លូវលេខ ៣៨០ មានប្រវែង ១,១៧ គ.ម ។ គម្រោងនេះ មានរយៈពេលអនុវត្តចំនួន ៥ ឆ្នាំ ២ ខែ (៦២ ខែ) និងរយៈពេលសាងសង់ចំនួន ៣ ឆ្នាំ ៩ ខែ (៤៧ខែ) ។

ជារួម, គិតចាប់ពីឆ្នាំ ២០០១ រហូតមកដល់ដំណាច់ឆ្នាំ ២០២២ នេះ, សាធារណរដ្ឋកូរ៉េបានផ្តល់ឥណទានសម្បទានដល់កម្ពុជាសរុបប្រមាណ ១,៦ ពាន់លានដុល្លារអាមេរិក តាមរយៈមូលនិធិសហប្រតិបត្តិការអភិវឌ្ឍន៍សេដ្ឋកិច្ច (EDCF) នៃធនាគារ The Export-Import Bank of Korea (Korea Eximbank) សម្រាប់គម្រោងអភិវឌ្ឍន៍នានា ដែលជាគម្រោងក្នុងវិស័យអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ស្របទៅតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, យុទ្ធសាស្ត្រចតុកោណគ្រប់ដំណាក់កាល របស់រាជរដ្ឋាភិបាលកម្ពុជា និងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ដែលមានវិស័យ ដូចជា ផ្លូវថ្នល់, ប្រព័ន្ធធារាសាស្ត្រ, ថាមពល, ទឹកស្អាតនិងអនាម័យ, សុខាភិបាល និងវិស័យទូរគមនាគមន៍ ។